យើងសង្ឃឹមថា ពិព័រណ៍នេះនឹងផ្តល់ពន្លឺខ្លះដល់ដំណើរទស្សនកិច្ចកាលពីឆ្នាំ១៩៧៨ ផ្តល់ចំណេះដឹង និងបង្កើតការពិភាក្សាអំពីតួនាទីរបស់សហគមន៍អន្តរជាតិក្នុងការចូលរួមចំណែកឬមិនចូលរួមចំណែកពីអតីតកាលនិងបច្ចុប្បន្ន ។ យើងក៏សង្ឃឹមថា ពិព័រណ៍និងសិក្ខាសាលានេះនឹងលើកទឹកចិត្តឲ្យសមាជិកដទៃទៀតនៃគណៈប្រតិភូស៊ុយអែដដែលអញ្ជើញមកធ្វើទស្សនកិច្ចនៅប្រទេសកម្ពុជាកាលពីឆ្នាំ១៩៧៨ ឲ្យចេញមកចែករំលែកជាមួយពិភពលោកនូវរឿងរ៉ាវ បទពិសោធន៍ និងឯកសាររបស់ខ្លួន ។ សំខាន់ជាងនេះទៅទៀត ពិព័រណ៍នេះប្រហែលជានាំមកនូវការផ្សះផ្សារសម្រាប់ប្រជាជនកម្ពុជា ជាពិសេសអ្នកដែលនៅរស់រានមានជីវិតមកដល់បច្ចុប្បន្ន ដែលមានចម្ងល់អស់រយៈពេលសាមសិបឆ្នាំថា គណៈប្រតិភូបរទេសទាំងនោះដែលមកធ្វើទស្សនកិច្ចនៅប្រទេសកម្ពុជាក្នុងរបបខ្មែរក្រហម ហេតុអ្វីក៏មិនជួយសង្គ្រោះប្រជាជនកម្ពុជា ។ ខណៈដែលតុលាការខ្មែរក្រហមប្រហែលជាអាចត្រួសត្រាយផ្លូវសម្រាប់ដំណើរការផ្សះផ្សារសង្គមកម្ពុជាទាំងមូលការចូលរួមចំណែករបស់បុគ្គលម្នាក់ៗនៅក្នុងដំណើរការនេះមានសារៈសំខាន់ណាស់ មិនថាបុគ្គលនោះជាជនរងគ្រោះ ជាអតីតជនដៃដល់ ឬជាអ្នកឈរឱបដៃមើល បើទោះជាអ្នកទាំងនោះមានចេតនាចូលរួមចំណែក ឬត្រូវបានបង្ខំឲ្យប្រព្រឹត្តបទឧក្រិដ្ឋ ឬបានគាំទ្រផ្នែកស្មារតី ឬនៅស្ងៀមមិនបញ្ចេញប្រតិកម្មអ្វីទាំងអស់ក៏ដោយ ។ ចំណុចចុងក្រោយនេះអាចជាមូលហេតុសំខាន់បំផុតដែល ហ្គុនណា រិលត្រឡប់មកប្រទេសកម្ពុជាជាថ្មីម្តងទៀត ។

## ជំនួយឧបត្ថម្ភ

ថវិការចំណាយក្នុងគម្រោងនេះជាអំណោយសប្បុរសរបស់ភ្នាក់ងារអភិវឌ្ឍអន្តរជាតិរបស់សហរដ្ឋអាមេរិក (USAID) និងភ្នាក់ងារអភិវឌ្ឍអន្តរជាតិរបស់ប្រទេសស៊ុយអែដ (Sida) ។

## សេចក្តីថ្លែងអំណរគុណ

សៀវភៅនេះបោះពុម្ពឡើងក្រោមជំនួយនិងការជ្រោមជ្រែងរបស់បុគ្គលនិងវិទ្យាស្ថានមួយចំនួន ។ បុគ្គលសំខាន់បំផុតដែលគាំទ្រខ្ញុំ គឺជនរងគ្រោះនៃរបបខ្មែរក្រហម ដែលភាគច្រើនខ្ញុំមិនបានស្គាល់ ប៉ុន្តែគាត់បានបញ្ចេញអំពីរឿងរ៉ាវនៃការជីវិតរបស់គាត់នៅក្រោមរបបខ្មែរក្រហម ។ រឿងរ៉ាវដែលគាត់បានរៀបរាប់ប្រាប់បានធ្វើឲ្យខ្ញុំមានការយល់ដឹងប្រសើរជាងមុនអំពីរឿងរ៉ាវដ៏គួរឲ្យភ័យរន្ធត់ដែលលាក់បាំងនៅពីក្រោយមុខមាត់ស្អាតស្អំរបស់របបខ្មែរក្រហមដែលយើងបានឃើញក្នុងអំឡុងពេលទស្សនកិច្ចរបស់យើង ។

ខ្ញុំក៏សូមថ្លែងអំណរគុណលោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា ។ គាត់គឺជាអ្នកផ្តួចផ្តើមគំនិតក្នុងការបោះពុម្ពផ្សាយសៀវភៅនេះនិងការរៀបចំតាំងពិព័រណ៍ និងបានជួយកែសម្រួលសៀវភៅនេះ ។ អរគុណចំពោះ ហ៊ុយ សោភ័ណ និង សារ៉ា ឌីកកិន ដែលបានរៀបចំគម្រោងថវិកា ។ អរគុណចំពោះ ចូអែល ប្រ៊ីងគ្លី ដែលបានជួយកែសម្រួល ។ អរគុណចំពោះ អ៊ីវីនទី វ៉ុង ដែលបានរៀបចំក្រាហ្វិកសៀវភៅនេះ ។ អរគុណចំពោះ ស៊ឹម សុភ័ក្ត្រ និង គឹម សុវណ្ណដានី ដែលជួយចាត់ចែងការបោះពុម្ពផ្សាយ ។ អរគុណចំពោះ សាន់ កល្យាណ នៅមជ្ឈមណ្ឌលឯកសារកម្ពុជា និង លី ដារ៉ាវុធ នៅវិទ្យាស្ថានវ៉េយ៉ំ ដែលបានរៀបចំការតាំងពិព័រណ៍នៅក្នុងប្រទេសកម្ពុជា ។ អរគុណ សើ សាយ្យាណា និង ម៉ម កល្យានី ដែលបានរៀបចំការតាំងពិព័រណ៍នៅឯការិយាល័យអង្គជំនុំជម្រះវិសាមញ្ញក្នុងប្រព័ន្ធតុលាការកម្ពុជា ។ អរគុណ ហេដា អេគឺរិល ដែលបានអនុញ្ញាតឲ្យខ្ញុំប្រើប្រាស់រូបថតទាំងនេះ ។



## សៀវភៅកាតាឡុក

ប៉ាននរកកម្ពុជាប្រជាធិបតេយ្យ ខែសីហា ឆ្នាំ១៩៧៨ (១០៨ ទំព័រ)
ភាសាខ្មែរ ៖ ចែកជូនដោយឥតគិតថ្លៃ
ភាសាអង់គ្លេស ៖ តម្លៃ ១៨ ដុល្លារ
មានលក់នៅហាងសៀវភៅ Monument Book
និងបន្ទប់ព័ត៌មានសាធារណៈនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

## ព័ត៌មានបន្ថែមសូមទាក់ទង ៖

សាន់ កល្យាណ, ប្រធានក្រុមនៃគម្រោងតាំងពិព័រណ៍និងសារៈមន្ទីរ

មជ្ឈមណ្ឌលឯកសារកម្ពុជា
ប្រអប់សំបុត្រលេខ ១១១០
ផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ ៖ ០២៣ ២១១ ៨៧៥ ឬ ០៩៩ ៧៩០ ២៨៩
ទូរសារ ៖ ០២៣ ២១០ ៣៨៥
អ៊ីមែល ៖ truthkalyan@dccam.org
គេហទំព័រ ៖ www.dccam.org ឬ www.cambodiatribunal.org

◆ រក្សាសិទ្ធិ ◆







ពិព័រណ៍ជាលក្ខណៈអន្តរជាតិឆ្នាំ២០០៨

# ប៉ាននរកកម្ពុជាប្រជាធិបតេយ្យ ខែសីហា ឆ្នាំ១៩៧៨

ពិព័រណ៍រូបថតនិងសិក្ខាសាលាជាមួយ ហ្គុនណា បឺយស្ត្រម

មជ្ឈមណ្ឌលឯកសារកម្ពុជា



**ហុនណា បឺយស្រ្តម** មិនដែលវិលត្រឡប់មកមើលប្រទេសកម្ពុជាទាល់តែសោះចាប់តាំងពីដំណើរទស្សនកិច្ចរបស់គាត់កាលពីសាមសិបឆ្នាំមុន ។ ក្នុងរយៈពេល១៤ថ្ងៃ ក្នុងឆ្នាំ១៩៧៨ ហុនណា បានស្នាក់នៅក្នុងប្រទេសកម្ពុជាជាមួយនឹងតំណាងផ្សេងទៀតរបស់សមាគមមិត្តភាពស៊ុយអែដ-កម្ពុជា នៅក្នុងដំណើរទស្សនកិច្ចការទូតមួយដែលខ្មែរក្រហមមានបំណងប្រើប្រាស់ដើម្បីទាក់ទាញការគាំទ្រពីបណ្តាប្រទេសកម្មុយនីស្ត ។ នៅក្នុងអំឡុងពេលទស្សនកិច្ចគណៈប្រតិភូត្រូវបានកម្មាភិបាលខ្មែរក្រហមនាំមើលទីកន្លែងជាច្រើននៅទីក្រុងភ្នំពេញ ខេត្តកណ្តាល កំពង់ចាម កំពង់ធំ សៀមរាប កំពត និងក្រុងកំពង់សោម ។ ហុនណា បានទៅមើលមន្ទីរពេទ្យរោងចក្រ សាលារៀន និងប្រជាជនធ្វើការងារនៅតាមវាលស្រែ ការដ្ឋានជីកប្រឡាយ និងនៅកន្លែងផ្សេងៗទៀត ។ គាត់ថែមទាំងបានទទួលទានអាហារពេលល្ងាចជាមួយ ប៉ុល ពត និង អៀង សារី ដែលជាមេដឹកនាំនៃរបបកម្ពុជាប្រជាធិបតេយ្យទៀតផង ។ ខណៈពេលដែលគណៈប្រតិភូស៊ុយអែដកំពុងតែទទួលទានអាហារនិងជល់កែវស្រាជាមួយមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម ប្រទេសកម្ពុជាទាំងមូលកំពុងតែស្ថិតនៅក្នុងសភាពខ្ទេចខ្ទាំ៖ ប្រជាជនកម្ពុជាកំពុងតែស្លាប់ បាក់កម្លាំង ស្រេកឃ្លាន និងខំប្រឹងសម្របខ្លួនដើម្បីរស់នៅក្នុងប្រទេសដែលកំពុងតែវិនាសហិនហោច ។ ក្រោយពេលវិលត្រឡប់ទៅប្រទេសស៊ុយអែដវិញ គណៈប្រតិភូបានលើកសរសើរអំពីកម្ពុជាថា គឺជាបដិវត្តន៍គំរូមួយ បើទោះបីជាទើបនឹងចាប់ផ្តើមនិងមិនទាន់ល្អឥតខ្ចោះក៏ដោយ ។ ជាងនេះទៅទៀត គណៈប្រតិភូថែមទាំងបង្ហាញឲ្យឃើញជំនឿមុតមាំថា របបកុម្មុយនីស្តអាចជាជម្រើសដ៏ល្អបំផុតសម្រាប់ប្រជាជនកម្ពុជា ។ រហូតដល់ពេលដែលបានឃើញជនភៀសខ្លួនកម្ពុជារាប់ម៉ឺននាក់ភៀសខ្លួនចូលទៅក្នុងទឹកដីថៃ ទើបគណៈប្រតិភូដឹងថាខ្លួនបានយល់ខុសទាំងស្រុងចំពោះបដិវត្តន៍កម្ពុជា ។ នៅក្នុងអំឡុងទស្សនកិច្ច ហុនណា និងមិត្តរួមដំណើររបស់គាត់បានថតរូបភាពនិងភាពយន្តឯកសារនៅទីកន្លែងមួយចំនួនដែលគាត់បានទៅដល់ ។ បច្ចុប្បន្ន ខ្សែភាពយន្តឯកសារនោះកំពុងស្ថិតនៅក្រោមការថែរក្សារបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។





នៅថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៨ ខាងមុខនេះ ហុនណា នឹងវិលត្រឡប់មកប្រទេសកម្ពុជាជាថ្មីម្តងទៀត និងជាលើកទីមួយបន្ទាប់ពីទស្សនកិច្ចរបស់គាត់កាលពីឆ្នាំ១៩៧៨ ។ គាត់នឹងជួបសន្ទនានិងពិភាក្សាជាមួយមេឃុំចំនួន៤៥០នាក់និងប្រជាជននៅតាមភូមិឃុំនិយាយប្រាប់ប្រជាជនកម្ពុជានិងពិភពលោកអំពីអ្វីដែលគាត់បានឃើញ បានធ្វើមិនដឹងមិនឮនិងអ្វី ដែលគាត់មិនបានឃើញទាល់តែសោះនៅក្នុងអំឡុងពេលទស្សនកិច្ច ។ ជាមួយនឹងការវិលត្រឡប់មកប្រទេសកម្ពុជាជាថ្មីម្តងទៀតរបស់ ហុនណា បឺយស្រ្តម, មជ្ឈមណ្ឌលឯកសារកម្ពុជាសហការជាមួយ វេទិកាប្រវត្តិសាស្រ្តរស់ នៅប្រទេសស៊ុយអែដ បានរៀបចំការតាំងពិព័រណ៍រូបថតមួយដែលមានចំណងជើងថា “ប៉ាននរកកម្ពុជាប្រជាធិបតេយ្យ ខែសីហា ឆ្នាំ១៩៧៨” ។ រូបថតដែលប្រើប្រាស់នៅក្នុងពិព័រណ៍នេះ គឺជារូបថតដែលថតដោយ ហុនណា និងមិត្តរួមដំណើររបស់គាត់ក្នុងអំឡុងពេលទស្សនកិច្ចកាលពីឆ្នាំ១៩៧៨ និងដែលយើងមិនធ្លាប់បានឃើញពីមុនមក ។ វាគឺជារូបពណ៌ធម្មជាតិដ៏ស្រស់ស្អាត ផ្ទុយពីរូបថតភាគច្រើនដែលថតក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យជារូបស-ខ្មៅ ។ ពិព័រណ៍នេះនឹងចាប់ផ្តើមបើកបង្ហាញសាធារណជននៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៨ នៅវិទ្យាស្ថានវ៉ៃយំ នៅរាជធានីភ្នំពេញ ព្រមទាំងសិក្ខាសាលាមួយនៅវិទ្យាស្ថានជាតិអប់រំដែលមាន ហុនណា បឺយស្រ្តម ជាវាគ្មិនពិសេស ។ ពិព័រណ៍នេះក៏នឹងមានដាក់តាំងនៅសារៈមន្ទីរខុក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បន្ទាប់មកនឹងធ្វើដំណើរទៅខេត្តកំពង់ចាម តាកែវ និងបាត់ដំបង ។ ពិព័រណ៍ដូចគ្នានេះក៏នឹងបើកបង្ហាញនៅទីស្នាក់ការវេទិកាប្រវត្តិសាស្រ្តរស់ក្នុងទីក្រុងស្តុកខូម ប្រទេសស៊ុយអែដ ក្នុងរដូវក្តៅឆ្នាំ២០០៩ និងធ្វើដំណើរជុំវិញប្រទេសស៊ុយអែដចាប់ពីដើមឆ្នាំ២០១០ ។



*ពីលើចុះក្រោម ពីឆ្វេងទៅស្តាំ : អតីតស្ថានីយ៍រថយន្តក្រុងនៅខេត្តកំពង់ចាម, ក្រុមគ្រួសារមកពីទីក្រុង, កុមារីនិងគ្រូបង្រៀននៅសហករណ៍, កុមារនៅសហករណ៍*

“ប៉ាននរកកម្ពុជាប្រជាធិបតេយ្យ ខែសីហា ឆ្នាំ១៩៧៨” នឹងប្រាប់រឿងរ៉ាវតាមរយៈម៉ាស៊ីនថតរូបរបស់ ហុនណា ដែលបានមកធ្វើទស្សនកិច្ចនៅប្រទេសកម្ពុជាកាលពីឆ្នាំ១៩៧៨ ។ វាគួរឲ្យចម្លែកបន្តិចត្រង់ថា រូបថតមួយចំនួននៅក្នុងពិព័រណ៍នេះ បង្ហាញឲ្យឃើញទីក្រុងភ្នំពេញដែលស្ងាត់ជ្រងំ ព្រះបរមរាជវាំង ប្រាសាទអង្គរវត្ត និង ហុនណា និងសមាជិកដទៃទៀត នៃគណៈប្រតិភូដែលមានទឹកមុខញញឹមរីករាយក្នុងឱកាសសន្ទនាជាមួយកម្មាភិបាលខ្មែរក្រហមនៅជនបទ ។ រូបថតមួយចំនួនទៀត បង្ហាញឲ្យឃើញស្ថានភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាជនដែលក្រឡេកមួយភ្លែតទៅធ្វើឲ្យយើងជឿជាក់ថាល្អពិតមែន គឺការទទួលទានអាហាររួម ធ្វើការងារនៅវាលស្រែ លើកទំនប់និងជីកប្រឡាយ ។ ដូចជាឯកសារជាច្រើនទៀតដែលសរសេរឡើងដោយរបបខ្មែរក្រហមដែរ រូបថតរបស់ ហុនណា មិនបានបង្ហាញឲ្យឃើញទារុណកម្ម ភាពស្រេកឃ្លាន ការស្លាប់រង្គាល និងការបាក់ទឹកចិត្តដែលគ្រប់គ្នាល្បីអំពីខ្មែរក្រហមនោះឡើយ ។ កង្វះខាតនេះបង្កើតឲ្យមានសំណួរថា តើអ្វីទៅជាមូលហេតុនៃការគាំទ្ររបស់គណៈប្រតិភូស៊ុយអែដចំពោះខ្មែរក្រហម? តើកម្មាភិបាលខ្មែរក្រហមបានរៀបចំទុកជាមុននូវអ្វីៗដែលគណៈប្រតិភូបានឃើញ ឬក៏គណៈប្រតិភូខ្លួនឯងមានចេតនាជឿទាំងងងឹតងងុលចំពោះស្ថានភាពដែលនៅជុំវិញខ្លួន? តើគណៈប្រតិភូស៊ុយអែដគឺជាអ្នកឈរឱបដៃមើល ឬក៏ជាជនរងគ្រោះដោយត្រូវខ្មែរក្រហមបោកប្រាស់ដែរ?